ថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2021

# សេចក្ដីជូនដំណឹងអំពី ការចាក់ដូសជំរុញ(លើកទី3) វ៉ាក់សាំងការពារមេរោគកូរ៉ូណា




## ដំណើរការនៃការទទួលបានការចាក់វ៉ាក់សាំង

## 1 បង្កាន់ដៃចាក់វ៉ាក់សាំងត្រូវបានបញ្ជូនទៅដល់អ្នក



**អ្នកដែលបានទទួលបង្កាន់ដៃ នឹងអាចចាក់វ៉ាក់សាងបាន។**

*ការចាប់ផ្ដើមចុះឈ្មោះទទួលការណាត់ដើម្បីចាក់ដូសជំរុញ អាចខុសគ្នាទៅតាមភូមិ សង្កាត់ ក្រុងនីមួយៗ។

- សម្រាប់តែអ្នកមានអាយុ 18ឆ្នាំឡើងគិតត្រឹមថ្ងៃចាក់។

## 2 ស្វែងរកស្ថាបនវេជ្ជសាស្ត្រ/ទីតាំងចាក់វ៉ាក់សាំង

**សូមស្វែងរកស្ថាបនវេជ្ជសាស្ត្រ ឬទីតាំងចាក់វ៉ាក់សាំងដែលអ្នកអាចចាក់វ៉ាក់សាំងបាន តាមរយៈអ៊ីនធើណែត ឬការផ្សព្វផ្សាយរបស់ក្រុងស្រុកខណ្ឌឃុំសង្កាត់ភូមិ។ គួរបញ្ជាក់ថា ក៏មានករណីដែលបុគ្គលិកផ្នែកវេជ្ជសាស្ត្រជាដើមអាចចាក់នៅស្ថាប័នវេជ្ជសាស្ត្រដែលខ្លួនបម្រើការងារដែរ។**

**ព័ត៌មានលម្អិត សូមបញ្ជាក់ជាមួយកន្លែងធ្វើការរបស់អ្នក។**

គេហទំព័រណែនាំទូទៅអំពីការចាក់វ៉ាក់សាំង

"covid-19 vaccine navi"

https://v-sys.mhlw.go.jp

*សូមសាកសួរភូមិ សង្កាត់ ក្រុងមូលដ្ឋានរបស់អ្នក ប្រសិនបើអ្នកមិនអាចស្វែងរកស្ថាបនវេជ្ជសាស្ត្រ ឬកន្លែងចាក់វ៉ាក់សាំងបាន។

*ជាគោលការណ៍ ការចាក់វ៉ាក់សាំងត្រូវធ្វើឡើងនៅភូមិ សង្កាត់ ឬក្រុងដែលអ្នកបានចុះបញ្ជីលំនៅដ្ឋាន(ទីលំនៅចុះបញ្ជី) លើកលែងចំពោះអ្នកដែលកំពុងសម្រាកព្យាបាល ឬស្នាក់នៅមណ្ឌលចាស់ជរា ជាដើម។ ចំពោះការចាក់វ៉ាក់សាំងនៅកន្លែងផ្សេងពីទីលំនៅចុះបញ្ជី សូមមើលនៅខាងក្រោយ។

*អ្នកមិនអាចធ្វើការចុះឈ្មោះណាត់ទុកមុន តាមរយៈគេហទំព័រ covid-19 vaccine navi ដោយផ្ទាល់បានទេ។

## 3 សូមធ្វើការចុះឈ្មោះណាត់ទុកជាមុន ដើម្បីចាក់វ៉ាក់សាំង

ចាក់វ៉ាក់សាំង **ឥតគិតថ្លៃ** (ឧបត្ថម្ភទាំងស្រុងដោយរដ្ឋាភិបាល)

### សូមទាក់ទងស្ថាបនវេជ្ជសាស្ត្រ ឬភូមិ សង្កាត់ ក្រុងដែលកំពុងចុះឈ្មោះទទួលការណាត់

**ទីតាំងចាក់វ៉ាក់សាំងនៅភូមិ សង្កាត់ ក្រុង** — មណ្ឌលផ្ដល់ព័ត៌មាន :

**ស្ថាបនវេជ្ជសាស្ត្រដែលត្រូវបានកំណត់នៅជិតទីតាំងអ្នក** — **ធ្វើការណាត់ដោយផ្ទាល់ជាមួយស្ថាបនវេជ្ជសាស្ត្រ** (ទូរស័ព្ទ ឬអ៊ីនធើណែតជាដើម)



ឯកសារមួយឈុតក្នុងស្រោមសំបុត្រ

\+



ប័ណ្ណលេខសំគាល់អត្តសញ្ញាណ ។ល។

**នៅថ្ងៃចាក់ត្រូវយកជាប់ខ្លួន**

- **ឯកសារមួយឈុតក្នុងស្រោមសំបុត្រ ដែលមានភ្ជាប់ជាមួយសេចក្ដីជូនដំណឹងនេះ**
- **ឯកសារបញ្ជាក់អត្តសញ្ញាណ(ប័ណ្ណលេខសំគាល់អត្តសញ្ញាណ ប័ណ្ណបើកបរ ប័ណ្ណធានារ៉ាប់រងសុខភាព។ល។)**

* ក្នុងស្រោមសំបុត្រមានភ្ជាប់**"បែបបទត្រួតពិនិត្យវេជ្ជសាស្ត្របឋមដែលមានភ្ជាប់បង្កាន់ដៃចាក់វ៉ាក់សាំង"**និង**"ប័ណ្ណបញ្ជាក់ការចាក់វ៉ាក់សាំងរួចរាល់"** ។ សូមរក្សាកុំឲ្យបាត់បង់។

(ក៏អាចមានករណីដែលបង្កាន់ដៃចាក់វ៉ាក់សាំងនិងប័ណ្ណបញ្ជាក់ការចាក់វ៉ាក់សាំងរួចរាល់ ត្រូវបានបញ្ចូលគ្នាក្នុងឯកសារតែមួយផងដែរ។)

* សូមវាស់កម្ដៅរាងកាយរបស់អ្នកនៅផ្ទះ មុនពេលមកចាក់វ៉ាក់សាំង ហើយសូមកុំចាក់វ៉ាក់សាំង និងត្រូវទាក់ទងទៅកាន់មណ្ឌលព័ត៌មានភូមិ សង្កាត់ ក្រុង ឬស្ថាបនវេជ្ជសាស្ត្រដែលអ្នកបានណាត់ដើម្បីចាក់វ៉ាក់សាំងនោះភ្លាម ប្រសិនបើអ្នកមានជំងឺគ្រុនក្ដៅ ឬមានអារម្មណ៍មិនស្រួលខ្លួន។

* ពេលទៅចាក់វ៉ាក់សាំង សូមទៅដោយស្លៀក**សម្លៀកបំពាក់ដែលអាចលាត់បញ្ចេញស្មាបានលឿន**។

## ◎អ្នកដែលយើងសូមលើកទឹកចិត្តឲ្យចាក់ដូសជំរុញជាពិសេស

- "**អ្នកដែលមានកត្តាសុខភាពប្រឈមធ្ងន់ធ្ងរ**" ដូចជាមនុស្សចាស់ជរា អ្នកមានជំងឺប្រចាំកាយជាដើម
- "**អ្នកដែលមានការប៉ះពាល់ច្រើនជាមួយអ្នកដែលមានហានិភ័យវិវត្តធ្ងន់ធ្ងរខ្ពស់**" ដូចជាអ្នកពាក់ព័ន្ធ/អ្នកមើលថែទាំ(អ្នកធ្វើការផ្នែកមើលថែទាំជាដើម) ជាដើមនៃអ្នកដែលមានហានិភ័យវិវត្តធ្ងន់ធ្ងរខ្ពស់
- "**អ្នកដែលមានហានិភ័យប្រឈមនឹងវីរុសខ្ពស់ដោយហេតុផលការងារ**" ដូចជាបុគ្គលិកផ្នែកវេជ្ជសាស្ត្រជាដើម

## ◎អំពីការចាក់វ៉ាក់សាំងនៅទីតាំងផ្សេង ក្រៅពីកន្លែងដែលមានក្នុងសំបុត្រស្នាក់នៅ(ទីលំនៅចុះបញ្ជី)

- សម្រាប់អ្នកដែលត្រូវចាក់វ៉ាក់សាំងនៅស្ថាបនវេជ្ជសាស្ត្រ ឬមណ្ឌលចាស់ជរាដែលខ្លួនកំពុងស្នាក់នៅព្យាបាល ឬកំពុងស្នាក់នៅ
  ➡ **សូមពិគ្រោះជាមួយស្ថាបនវេជ្ជសាស្ត្រ ឬមណ្ឌលចាស់ជរានោះ។**
- សម្រាប់អ្នកដែលត្រូវចាក់វ៉ាក់សាំងនៅស្ថាបនវេជ្ជសាស្ត្រដែលខ្លួនកំពុងព្យាបាលជំងឺប្រចាំកាយ ➡ **សូមពិគ្រោះជាមួយស្ថាបនវេជ្ជសាស្ត្រនោះ។**
- សម្រាប់អ្នកដែលកន្លែងស្នាក់នៅខុសពីទីលំនៅចុះបញ្ជី ➡ **អាចមានករណីដែលអ្នកអាចទទួលវ៉ាក់សាំងនៅតំបន់ដែលកំពុងស្នាក់នៅបច្ចុប្បន្នបាន។** សូមស្វែងរកព័ត៌មាននៅគេហទំព័រ ឬសាកសួរការិយាល័យពិគ្រោះយោបល់ភូមិ សង្កាត់ ក្រុងដែលអ្នកកំពុងស្នាក់នៅបច្ចុប្បន្ន។

## ◎ដើម្បីទទួលការចាក់វ៉ាក់សាំង ចាំបាច់ត្រូវមានការព្រមព្រៀងពីសាមីខ្លួន។

សូមធ្វើការសម្រេចចិត្តចាក់វ៉ាក់សាំងដោយផ្អែកលើឆន្ទៈស្ម័គ្រចិត្តរបស់សាមីខ្លួន បន្ទាប់ពីបានស្វែងយល់ត្រឹមត្រូវអំពីកម្រិតប្រសិទ្ធភាព និង

ហានិភ័យ ផលរំខាននៃការចាក់វ៉ាក់សាំងការពារការឆ្លងនេះ។ ការចាក់វ៉ាក់សាំងនឹងមិនត្រូវបានអនុវត្តឡើយ ប្រសិនបើគ្មានការព្រមព្រៀងពីសាមីខ្លួន។

មិនអនុញ្ញាតអោយមានការបង្ខំឲ្យចាក់ ឬការរើសអើងចំពោះបុគ្គលដែលមិនបានចាក់ ពីសំណាក់កន្លែងការងារ ឬអ្នកជុំវិញឡើយ។

## ◎ប្រព័ន្ធជំនួយចំពោះការរងផលប៉ះពាល់សុខភាពដោយការចាក់វ៉ាក់សាំង

នៅក្នុងការចាក់វ៉ាក់សាំងបង្ការ អាចមានករណីកើតមានផលប៉ះពាល់សុខភាព (កើតជំងឺផ្សេងៗ ឬបន្សល់នូវពិការភាព)។ ទោះបីជាករណីកម្រ ប៉ុន្តែក៏មិនអាចសន្មត់ថាគ្មានទាំងស្រុងបានឡើយ ហេតុនេះទើបប្រព័ន្ធជំនួយនេះត្រូវបានបង្កើតឡើង។

អំពីបែបបទចាំបាច់ផ្សេងៗដើម្បីដាក់ពាក្យស្នើសុំ សូមប្រឹក្សាជាមួយភូមិ សង្កាត់ ក្រុង មូលដ្ឋានដែលអ្នកបានចុះបញ្ជីស្នាក់នៅ។

## ◎សូមបន្តអនុវត្តវិធានការការពារការឆ្លងដូចជាពាក់ម៉ាសជាដើម ទោះបីជាបានទទួលការចាក់វ៉ាក់សាំងហើយក៏ដោយ។

វ៉ាក់សាំងការពារមេរោគកូរ៉ូណា ត្រូវបានបញ្ជាក់ថាមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្ការការចេញរោគសញ្ញានៃជំងឺកូវីដ-19 ប៉ុន្តែប្រសិទ្ធភាពនោះគឺមិនមែន 100% នោះទេ។ ម្យ៉ាងទៀត ក៏មានឥទ្ធិពលដោយសារការបំប្លែងរបស់វីរុសផងដែរ។

អាស្រ័យហេតុនេះ សូមលោកអ្នកបន្តអនុវត្តវិធានការការពារការឆ្លង ដែលមានដូចជា ការជៀសវាង ["ជិត" ទាំង3 (កន្លែងជិតកកកុញ ការប៉ះពាល់ជិតស្និទ្ធ កន្លែងបិទជិត)/ អនុវត្ត 3កុំ (កុំនៅកន្លែងកកកុញ កុំប៉ះពាល់ជិតស្និទ្ធ កុំនៅកន្លែងបិទជិត) ការពាក់ម៉ាស និងការលាងដៃនឹងសាប៊ូ ឬសម្លាប់មេរោគដោយអាល់កុលលាងសំអាតដៃជាដើម។

**សូមបន្តអនុវត្តវិធានការការពារការឆ្លង។**




**ជៀសវាង [ "ជិត" ទាំង3 (កន្លែងជិតកកកុញ ការប៉ះពាល់ជិតស្និទ្ធ កន្លែងបិទជិត)] / អនុវត្ត 3កុំ (កុំនៅកន្លែងកកកុញ កុំប៉ះពាល់ជិតស្និទ្ធ កុំនៅកន្លែងបិទជិត)**

**ចំពោះព័ត៌មានលម្អិតអំពីប្រសិទ្ធភាពនិងសុវត្ថិភាពរបស់វ៉ាក់សាំងការពារមេរោគកូរ៉ូណា សូមមើលគេហទំព័រក្រសួងសុខាភិបាលការងារនិងសុខុមាលភាព ត្រង់ទំព័រ "អំពីវ៉ាក់សាំងការពារមេរោគកូរ៉ូណា"។**

សុខាភិបាលការងារនិងសុខុមាលភាព វីរុសកូរ៉ូណា វ៉ាក់សាំង | ស្វែងរក

ករណីមិនអាចមើលគេហទំព័រនេះបាន សូមប្រឹក្សាជាមួយភូមិ សង្កាត់ ក្រុងដែលអ្នករស់នៅ។

សាកសួរព័ត៌មានតាមរយៈ: